សិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១
នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣

# ខ្លឹមសារសំខាន់ៗ របស់ របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣

អគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ

ថ្ងៃពុធ ១៣រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២២

## មាតិកា

១. ប្រវត្តិដើម និងគោលបំណង

២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣

៣. តម្លៃដែលត្រូវបានចំណាយ ធនធាន និងការកំណត់កម្មវិធីចំណាយ

៤. សេចក្ដីសន្និដ្ឋាន

5

## ១. ប្រវត្តិដើម និងគោលបំណង

- ផ.យ.អ.ជ. ២០១៩-២០២៣ ត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៩។
- ត្រូវបានទទួលបានការអនុម័តពីរដ្ឋសភា កាលពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩។
- ត្រូវបានទទួលបានការអនុម័តពី ព្រឹទ្ធសភាកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៩។
- ព្រះករុណាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានឡាយព្រះហស្ថលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ ពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩។

3

## ១. ប្រវត្តិដើម និងគោលបំណង (ត)

- ផ្អែកលើពូកទី៦ នៃ ផ.យ.អ.ជ. ផែនការនេះត្រូវ ធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ប្រចាំឆ្នាំ និងពាក់កណ្តាលអាណត្តិ។
- ឆ្នាំ២០២១ គឺជាឆ្នាំពាក់កណ្តាលអាណត្តិរបស់ផែនការ។
- ក្រសួងផែនការបានដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ រៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ ដោយពិនិត្យមើលពីវឌ្ឍនភាព ពីដើមឆ្នាំ២០១៩ ដល់ ខែមិថុនា ឆ្នាំ២០២១។
- ក្រសួងផែនការទទួលបានសិទ្ធិប្រទានពីរាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១។
- រៀបចំកិច្ចប្រជុំអន្តរក្រសួង ដើម្បីណែនាំ ពីការរៀបចំ និងផ្តល់ធាតុចូលសម្រាប់ រៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣ (៣ សីហា ២០២១)។

4

## ១. ប្រវត្តិដើម និងគោលបំណង (ត)

- រៀបចំសេចក្តីព្រាង ផ្អែកលើធាតុចូលពីក្រសួង ស្ថាប័ន ព័ត៌មាននិងគោលនយោបាយថ្មីៗ។
- រៀបចំកិច្ចប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេស ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (២៣ ធ្នូ ២០២១)។
- រៀបចំកិច្ចប្រជុំអន្តរក្រសួងកម្រិតនយោបាយ ដើម្បីពិនិត្យនិងផ្តល់ការឯកភាពលើសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (១៧ មីនា ២០២២)។
- រៀបចំកិច្ចប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងផ្តល់ការឯកភាពលើសេចក្តីព្រាងរបាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ ចុងក្រោយ (២៨ កក្កដា ២០២២)។
- ទទួលការអនុម័តពីរាជរដ្ឋាភិបាលកម្ពុជា ថ្ងៃទី៩ កញ្ញា ឆ្នាំ២០២២។

5

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣

- របាយការណ៍បែងចែកជា ៧ជំពូក៖
  - ➢ ជំពូកទី១៖ សេចក្តីផ្តើម
  - ➢ ជំពូកទី២៖ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច
  - ➢ ជំពូកទី៣៖ សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗ
  - ➢ ជំពូកទី៤៖ ជំហានបន្ទាប់។
  - ➢ ជំពូកទី៥៖ តម្លៃដែលត្រូវចំណាយ ធនធាន និងការកំណត់កម្មវិធីចំណាយ។
  - ➢ ជំពូកទី៦៖ ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។
  - ➢ ជំពូកទី៧៖ សេចក្តីសន្និដ្ឋាន

6

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច (២០១៨ ដល់ ២០២១)

| | ២០១៨ | ២០១៩ | ២០២០ | កក្កដា ២០២១ |
|---|---|---|---|---|
| កំណើនផលិតផលក្នុងស្រុកសរុបពិត(%) | ៧,៥ | ៧,១ | -៣,១ | ២,៤ |
| ផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់(ដុល្លារអាម៉េរិក) | ១ ៥៦៣ | ១ ៧០០ | ១ ៦៥៣ | ១ ៧៣០ |
| ការវិនិយោគធៀបនឹងផលិតផលក្នុងស្រុកសរុប(%) | ៣១,១ | ៣២,៦ | ៣៥,៩ | ៣៥,៨ |
| អតិផរណា(%) | ២,៥ | ១,៨ | ២,៩ | ៣,៤ |
| អត្រាប្តូរប្រាក់(រៀល/ដុល្លារអាម៉េរិក) | ៤ ០៤៥ | ៤ ០៥៥ | ៤ ០៨០ | ៤ ០៦៥ |

7

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ចំណូល ចំណាយ និងសន្តុល្យចំណូល

| | ២០១៨ | ២០១៩ | ២០២០ | កក្កដា ២០២១ |
|---|---|---|---|---|
| ចំណូល | ២១,៩% | ២៥,២% | ២១,៨% | ១៩,២% |
| ចំណាយ | ២៣,៤% | ២៥,៩% | ២៩,០% | ៣០,៥% |
| បំណុលធៀបនឹងផលិផលក្នុងស្រុកសរុប | ២១,៤% | ២០,៩% | ២៤,០៤% | |
| បំណុលធៀបនឹងការនាំចេញ | ២៨,៤% | ២៦,៧% | ៣២,៨% | |

8

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ការវិភាគពីចីរភាពបំណុល (%)

| | Wkuhvkrg | ២០១៨ | ២០១៩ | ២០២០ |
|---|---|---|---|---|
| បំណុលសាធារណៈសរុប ធៀបនឹង | | | | |
| ផលិតផលក្នុងស្រុកសរុប (%) | ៥៥ | ២១,៤ | ២០,៧៨ | ២៤,០៤ |
| បំណុលសាធារណៈនិងបំណុលសាធារណៈធានាបំណុលក្រៅប្រទេស ធៀបនឹង | | | | |
| ការនាំចេញ (%) | ១៨០ | ២៨,៤ | ២៦,៧ | ៣២,៨ |
| បំណុលសាធារណៈនិងបំណុលសាធារណៈធានាសេវាបំណុលក្រៅប្រទេស ធៀបនឹង | | | | |
| ចំណូល (%) | ១៨ | ៤,៩ | ៤,៥ | ៦,៣ |

9

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

**វឌ្ឍនភាពជញ្ជីងទូទាត់៖**

- ស្ថានភាពជញ្ជីងទូទាត់មានអតិរេកជាមធ្យមប្រមាណ ៤% ធៀបនឹង ផ.ស.ស. រយៈពេលពីឆ្នាំ២០១៩ ដល់ ឆមាសទី១ ឆ្នាំ២០២១។
- អតិរេកជញ្ជីងទូទាត់បានថយចុះពី ៥,៩% នៃ ផ.ស.ស.ក្នុងឆ្នាំ ២០១៨ មក ១% នៃផ.ស.ស.ក្នុងឆមាសទី១ ឆ្នាំ២០២១ ជាចម្បង ដោយសារការកើនឡើងឱនភាពគណនីចរន្តនិងសេវា។

10

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)




11

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)




12

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ១. ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចល្អ

#### ១.១- ការកែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័ន

- រាជរដ្ឋាភិបាលកម្ពុជាបានលើកកម្ពស់គុណភាពសេវាសាធារណៈនៅថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈក្រសួងមហាផ្ទៃ ដែលរួមមាន ការរៀបចំលិខិតបទដ្ឋាននានា ការអភិវឌ្ឍសមត្ថភាពមន្ត្រី ការដាក់ឱ្យអនុវត្តច្រកចេញចូលតែមួយ ការផ្ដល់លក្ខណៈងាយស្រួលដល់ប្រជាជនក្នុងការចេញចូលប្រទេសជិតខាង និង ការកែទម្រង់ផ្សេងៗ។
- ការរក្សាស្ថិរភាពនយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម ផ្ទៃក្នុង និងតាមព្រំដែនប្រទេសជិតខាង។
- ការបណ្ដុះបណ្ដាល និងអភិវឌ្ឍមន្ត្រី ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- សម្រួលការបើកបៀវត្សរ៍ជូនមន្ត្រីរាជការ បានឆាប់រហ័ស និងទាន់ពេល។

13

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ១. ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចល្អ (ត)

#### ១.១- ការកែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័ន (ត)

- កត្តាឆ្លងរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ ការប្រែប្រួលអាកាសធាតុ សង្គ្រាមពាណិជ្ជកម្មរវាងសហរដ្ឋអាម៉េរិកនិងចិន និងការរឹតត្បិតការនាំចូលទំនិញរបស់សហគមន៍អឺរ៉ុប បានធ្វើឱ្យការស្វែងរកប្រភពទុនវិនិយោគលើធនធានរូបវន្តកងទ័ពជួបការលំបាក។
- ការគ្រប់គ្រងនិងប្រើប្រាស់ធនធានរូបវន្តរបស់កងទ័ព នៅពុំទាន់ប្រើប្រាស់ឱ្យអស់សក្ដានុពលប្រកបដោយប្រសិទ្ធភាព ដើម្បីទាញប្រយោជន៍ឱ្យបានជាអតិបរមាសម្រាប់បង្កើន កម្រិតជីវភាពរស់នៅនិងការអភិវឌ្ឍរបស់អង្គភាព។

14

:

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ១. ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចល្អ (ត)

**១.២- ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ**

- រាជរដ្ឋាភិបាលកម្ពុជា បន្តអនុវត្តការងារប្រឆាំងអំពើពុករលួយស្របទៅតាមអភិក្រមទាំង៥ ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ និងវិធានការស្នូលទាំង៣ រួមមាន៖

  (១)ការពង្រឹងការអប់រំមិនឱ្យប្រព្រឹត្តអំពើពុករលួយ

  (២)ការបង្ការទប់ស្កាត់កុំឱ្យអាចប្រព្រឹត្តអំពើពុករលួយ និង

  (៣)ការបង្ក្រាបបទល្មើសពុករលួយ តាមរយៈ ការអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ។
- រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំសេចក្ដីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០២០-២០៣០ តែនៅមានបញ្ហា អនុវត្តមិនទាន់បានទូលំទូលាយ។
- រាជរដ្ឋាភិបាលកម្ពុជា ក៏បានរៀបចំសេចក្ដីព្រាងច្បាប់អធិការកិច្ច។

15

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ១. ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចល្អ (ត)

**១.៣- ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ**

- ដើម្បីពង្រឹងប្រសិទ្ធភាពការងាររបស់មន្ត្រីរាជការ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំវគ្គបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពតាមរយៈវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលា រយៈពេលខ្លីនិងវែង និងបានអនុវត្តការងារតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការងារអធិការកិច្ច។
- បន្តពង្រឹងការគ្រប់គ្រងការងារកំណែទម្រង់ និងកែសម្រួលរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

16

;

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ប. ២០១៩-២០២៣ (ត)

### ១. ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចល្អ (ត)

#### ១.៣- ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ (ត)

- លើកកម្ពស់ប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស នៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំនិងដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងធន ធានមនុស្សតាមបែបវិមជ្ឈការ។
- បន្តជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុ។
- ពង្រឹងការងារនីតិកម្ម ព្រមទាំងផ្ដោតការយកចិត្តទុកដាក់លើការងារព្រឹត្តិបត្រថ្កោលទោស ការលើកលែង និងការបន្ធូរបន្ថយទោស ដោះស្រាយ ការកកស្ទះសំណុំរឿង ការងារសន្ធានកម្មនិងយុត្តិធម៌មូលដ្ឋាន។

៣៦

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ប. ២០១៩-២០២៣ (ត)

### ១. ការបង្កើនល្បឿននៃការកែទម្រង់អភិបាលកិច្ចល្អ (ត)

#### ១.៤- ពង្រឹងអភិបាលកិច្ចក្នុងវិស័យឯកជន

- រាជរដ្ឋាភិបាល បានរៀបចំវេទិការាជរដ្ឋាភិបាល ផ្នែកឯកជនលើកទី ១៨ ដោយបានដាក់ចេញនូវវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ សំដៅពង្រឹងភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជា។

៣៦

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ២- បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

២.១- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

- ផ្តោតការយកចិត្តទុកដាក់ លើការពារអធិបតេយ្យជាតិនិងបូរណភាពទឹកដី ព្រមទាំងការទប់ស្កាត់និងប្រឆាំងដាច់ខាតរាល់សកម្មភាពខុសច្បាប់ បង្កអស្ថិរភាពនយោបាយបូចលាចលក្នុងសង្គម ព្រមទាំងបញ្ចៀសបាននូវអំពើភេរវកម្មមិនឱ្យកើតមានឡើងនៅកម្ពុជា។
- ការទប់ស្កាត់សកម្មភាពប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់។
- ការបន្តដោះស្រាយបញ្ហាព្រំដែនគោកនិងទឹកជាមួយប្រទេសជិតខាងដោយផ្អែកលើមូលដ្ឋានច្បាប់អន្តរជាតិ។
- ការពង្រឹងសុវត្ថិភាពចរាចរណ៍និងសណ្តាប់ធ្នាប់សាធារណៈ។

19

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ២- បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ(ត)

២.១- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ (ត)

- រាជរដ្ឋាភិបាលកម្ពុជា បានបន្តប្រយុទ្ធប្រឆាំង គ្រឿងញៀន ដោយផ្សព្វផ្សាយ និងអនុវត្តតាមទីសស្លោក ៣កុំ ១រាយការណ៍ គឺ ១- កុំពាក់ព័ន្ធ ២- កុំអន្តរាគមន៍ ៣- កុំលើកលែង និងត្រូវរាយការណ៍គ្រប់ករណីបទល្មើសគ្រឿងញៀន។

20

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ២- បរិស្ថានគ្រប់ដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល(ត)

### ២.២- បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ

- រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តការចុះបញ្ជីពាណិជ្ជកម្ម ការអនុវត្តកិច្ចការកែម្មសិទ្ធិបញ្ញា ការជំរុញការនាំចេញ នាំចូល តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ការត្រួតពិនិត្យទំនិញ ការពារអ្នកប្រើប្រាស់ និងកិច្ចការប្រកួតប្រជែង។
- ការរីករាលដាលនៃជំងឺកូវីដ-១៩ ធ្វើឱ្យខកខានក្នុងការអនុវត្តផែនការសកម្មភាព និងការរៀបចំវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា កិច្ចប្រជុំ។
- ច្បាប់និងលិខិតបទដ្ឋានសម្រាប់គាំទ្រដល់ដំណើរការអនុវត្តការងារនៅមិនទាន់មានគ្រប់គ្រាន់។

21

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ២- បរិស្ថានគ្រប់ដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល(ត)

### ២.២- បរិយាកាសអំណោយផល សម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ (ត)

- រាជរដ្ឋាភិបាលកម្ពុជា បានបញ្ចប់សេចក្ដីព្រាងច្បាប់ថ្មីស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា កំពុងបន្តរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីតំបន់សេដ្ឋកិច្ចពិសេស។
- សម្របសម្រួលរៀបចំវេទិកានិងកិច្ចប្រជុំជាមួយអ្នកវិនិយោគក្នុងនិងក្រៅប្រទេសនានា។
- បាននិងកំពុងសហការជាមួយចក្រភពអង់គ្លេស ក្នុងការអនុវត្តកម្មវិធីពន្លឿនការគាំទ្រសេដ្ឋកិច្ចក្នុងដំណាក់កាលជំងឺកូវីដ-១៩។

22

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.៥. ២០១៩-២០២៣ (ត)

២- បរិស្ថានគ្រប់ដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល(ត)

២.៣- ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ

- រាជរដ្ឋាភិបាលកម្ពុជា បានតស៊ូមតិយ៉ាងស្វិតស្វាញនៅលើសមរភូមិការទូតនិងសាធារណមតិ តបតទៅនឹងទង្វើជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា សកម្មភាពបំពានលើឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជា។
- បានចងក្រងនិងផ្សព្វផ្សាយឯកសារស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា វគ្គ១និងវគ្គ២។
- បានបង្ហាញពីសុឆន្ទៈកម្ពុជាក្នុងការបង្កើនបរិយាកាសសុខដុមនីយកម្មចំពោះកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលបរទេសនានា។

23

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.៥. ២០១៩-២០២៣ (ត)

២- បរិស្ថានគ្រប់ដណ្ដប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល(ត)

២.៣- ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ (ត)

- កម្ពុជាបាននិងកំពុងជំរុញការទូតសេដ្ឋកិច្ចយ៉ាងសកម្ម សំដៅកៀរគរវិនិយោគិនបរទេស ផ្សព្វផ្សាយអូសទាញភ្ញៀវទេសចរណ៍ ពង្រីកទីផ្សារសម្រាប់នាំចេញ ក៏ដូចជាការធ្វើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ជាមួយបណ្ដាប្រទេសជាមិត្តនានា។
- បានរៀបចំនិងអនុវត្តយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍនិងភាពជាដៃគូ ឆ្នាំ ២០១៩-២០២៣។
- បានកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីគាំទ្រការងារអាទិភាព និងវិធានការគន្លឹះនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា។

24

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ២- បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល(ត)

### ២.៤- ការពង្រឹងសមត្ថភាពកម្ពុជាដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក

- ដើម្បីជំរុញការធ្វើសមាហរណកម្ម ចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក រាជរដ្ឋាភិបាលកម្ពុជា បានពង្រឹងនិងពង្រីកទំនាក់ទំនងពាណិជ្ជកម្មជាមួយបណ្តាប្រទេសនានា ពង្រឹងកិច្ចការពិព័រណ៍ ពង្រឹងការអភិវឌ្ឍទីផ្សារនៅក្រៅប្រទេស។
- ទន្ទឹមនឹងនេះ បានរៀបចំផែនទីបង្ហាញផ្លូវក្នុងដំណើរការសមាហរណកម្មពាណិជ្ជកម្មកម្ពុជា អភិវឌ្ឍមជ្ឈមណ្ឌលព័ត៌មានពាណិជ្ជកម្មកម្ពុជា និងបានកែលម្អក្របខ័ណ្ឌគតិយុត្តលើផ្នែកធុរកិច្ច ពាណិជ្ជកម្ម និងវិនិយោគ។
- លទ្ធភាពនៅមានកម្រិត ក្នុងការអនុវត្តការងារនិងការបញ្ជ្រាបការយល់ដឹងដល់សាធារណជន ពិសេសស្តីពីស្ថានភាពនិងបរិបទនៃសកម្មភាពពាណិជ្ជកម្មក្នុងប្រទេស តំបន់ និងពិភពលោក។

25

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៣- ការអភិវឌ្ឍធនធានមនុស្ស

### ៣.១- ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

- រាជរដ្ឋាភិបាលកម្ពុជា បានបន្តពង្រឹងគុណភាពអប់រំក្នុងកម្រិតសិក្សាទាំងអស់ រួមមាន កម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា។
- ក្នុងរយៈពេលនៃការរីករាលដាលកូវីដ១៩ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវវិធានការចាំបាច់នានាឆ្លើយតបនឹង “គន្លងជីវិតថ្មីក្នុងវិស័យអប់រំ” ដើម្បីធានាឱ្យការរៀនសូត្ររបស់សិស្សបានពេញលេញ។
- មធ្យោបាយក្នុងការអនុវត្តការអប់រំពីចម្ងាយ មានដូចជាទូរទស្សន៍ ទូរសព្ទ កុំព្យូទ័រ កុំព្យូទ័របន្ទះ សន្លឹកកិច្ចការ សៀវភៅសិក្សាគោល ឯកសារផ្សេងៗ កម្មវិធី Zoom, Telegram, Messenger, Facebook, Google Meet, Google Classroom, E-Learning App, ប៉ុស្តិ៍ទូរទស្សន៍ …។

26

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៣- ការអភិវឌ្ឍធនធានមនុស្ស (ត)

### ៣.២- ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស

- រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ផែនការយុទ្ធសាស្ត្រសកម្មភាពធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្ដុះបណ្ដាល បច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៩-២០២៣។
- បានអនុវត្តសាកល្បងវិធីបណ្ដុះបណ្ដាលភាពជាដៃគូរវាងរដ្ឋនិងឯកជនលើវិស័យអាទិភាពនានា។
- បានបង្កើតក្រុមប្រឹក្សាជំនាញតាមវិស័យចំនួន៤ គឺវិស័យសំណង់នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ វិស័យអគ្គិសនីនៅវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ វិស័យមេកានិក រថយន្តនៅវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង និងវិស័យកម្មន្តសាលនៅវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា។



## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៣- ការអភិវឌ្ឍធនធានមនុស្ស (ត)

### ៣.៣- ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ

- ស្ថានភាពសុខភាពនិងសុខមាលភាពរបស់ប្រជាជនកម្ពុជា ត្រូវបានធ្វើឱ្យប្រសើរឡើង តាមរយៈការពង្រឹងនិងពង្រីកប្រព័ន្ធផ្ដល់សេវាថែទាំសុខភាពមានគុណភាព សុវត្ថិភាព ប្រសិទ្ធភាព ប្រកបដោយសមធម៌ និងពង្រីកការគ្របដណ្ដប់នៃប្រព័ន្ធគាំពារសុខភាពសង្គម។
- បានកាត់បន្ថយជាបន្តបន្ទាប់ការឈឺនិងស្លាប់ដោយជំងឺឆ្លង ជំងឺរ៉ាំរ៉ៃ។
- រាជរដ្ឋាភិបាលកម្ពុជា ក៏បានបន្តផ្ដោតការយកចិត្តទុកដាក់លើ សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងការផ្គត់ផ្គង់វិស័យទឹកស្អាត ។

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.៩. ២០១៩-២០២៣ (ត)

### ៣- ការអភិវឌ្ឍធនធានមនុស្ស (ត)

### ៣.៤- ការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម

- រាជរដ្ឋាភិបាលកម្ពុជា បន្តពង្រឹង សមភាពយេឌ័រ ក្នុងគ្រប់វិស័យ ទាំងក្នុងកម្លាំងពលកម្ម និងកម្រិតថ្នាក់ដឹកនាំ ឬអ្នកធ្វើសេចក្ដីសម្រេចិត្ត។
- ផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣(ឆ្នាំ២០១៩-២០២៣) បានអនុម័តនិងដាក់ឱ្យអនុវត្តជាផ្លូវការដោយរាជរដ្ឋាភិបាល និងមានការចូលរួមអនុវត្តពីគ្រប់ដៃគូពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

29

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.៩. ២០១៩-២០២៣ (ត)

### ៣- ការអភិវឌ្ឍធនធានមនុស្ស (ត)

### ៣.៤- ការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម (ត)

- សេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីសមភាពយេនឌ័រ ត្រូវបានតាក់តែងនិងមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយតំណាងក្រសួងស្ថាប័ន និងដៃគូពាក់ព័ន្ធនានា។
- ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ២០១៩-២០២៣ ត្រូវបានតាក់តែងនិងដាក់ឱ្យអនុវត្ត សម្រាប់ក្រសួងនិងមន្ទីរកិច្ចការនារីរាជធានី ខេត្ត។
- ផ្នត់គំនិតនិងឥរិយាបថគ្រួសារនិងសង្គមនៅបន្តរើសអើងលើតួនាទីស្ត្រី ក្នុងភាពជាអ្នកដឹកនាំ គឺជាកត្តារាំងដល់ការចូលរួមពេញលេញរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្ដីសម្រេច ក្នុងវិស័យសាធារណៈនិងនយោបាយ។

30

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច

៤.១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូនថាមពល និងឌីជីថល

- រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់មួយចំនួន ដូចជាច្បាប់ស្តីពីកំពង់ផែ ច្បាប់ស្តីពីការដឹកជញ្ជូនផ្លូវទឹកនិងសមុទ្រ ច្បាប់ស្តីពីអាជីវកម្មដឹកជញ្ជូនផ្លូវគោក ច្បាប់ស្តីពីទឹកកកខ្វក់ និងបានរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធមួយចំនួន។
- បានដាក់ឱ្យដំណើរការមជ្ឈមណ្ឌលផ្តល់សេវាសាធារណៈ នៅបណ្តាផ្សារទំនើបក្នុងរាជធានីភ្នំពេញ។
- បានរៀបចំផែនការមេបច្ចេកវិទ្យាសម្រាប់វិស័យសាធារណការនិងដឹកជញ្ជូន
- បានអភិវឌ្ឍផ្លូវក្រវ៉ាត់ក្រុង និងប្រព័ន្ធគ្រប់គ្រងព័ត៌មានផ្លូវថ្នល់។

31

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច (ត)

៤.១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូនថាមពល និងឌីជីថល (ត)

- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ផ្លូវហោះហើរ និងប្រព័ន្ធផ្កាយរណបនៅអាកាសយានដ្ឋានទាំងបី។
- បានធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិអាកាសចរស៊ីវិលកម្ពុជា ផ្នែកសន្តិសុខ(CCAR Part-17) តាមការណែនាំរបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ។
- បានរៀបចំសេចក្តីព្រាងកម្មវិធីជាតិកិច្ចសម្របសម្រួលដឹកជញ្ជូនផ្លូវអាកាស។
- បានធ្វើការសិក្សាសក្តានុពលនៃប្រភពថាមពលវារីអគ្គិសនីចំនួន១២កន្លែងបន្ថែមទៀត និងប្រភពថាមពលខ្យល់នៅក្នុងខេត្តចំនួន៦(មណ្ឌលគិរី កំពត កំពង់ស្ពឺ ព្រះសីហនុ កែប និងកំពង់ឆ្នាំង)។

32

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច (ត)

៤.១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល (ត)

- បានសិក្សាផែនការមេចំនួន២ ដើម្បីកំណត់ចក្ខុវិស័យនៃការអភិវឌ្ឍថាមពលអគ្គិសនីនៅកម្ពុជា(ឆ្នាំ២០២១-២០៤០)។
- បានពិនិត្យនិងរៀបចំគោលនយោបាយជាតិស្ដីពីប្រសិទ្ធភាពថាមពល និងរៀបចំការអនុវត្តគម្រោងប្រសិទ្ធភាពថាមពលនិងសន្សំសំចៃថាមពល។
- បានរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃថាមពលបរមាណូស៊ីវិល។

33

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច (ត)

៤.១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល (ត)

- បានជំរុញនិងបង្កើនលទ្ធភាពនៃការផ្ដល់សេវាប្រៃសណីយ៍ឱ្យកាន់តែទូលំទូលាយប្រកប ដោយគុណភាពនិងមានទំនុកចិត្ត។
- បានស្រាវជ្រាវលើបច្ចេកវិទ្យាឌីជីថល ដូចជាបច្ចេកវិទ្យាភាសានិងបញ្ញាសិប្បនិម្មិត និងចូលរួមកសាងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីឌីជីល និងជំរុញនវានុវត្តន៍ឌីជីថល តាមរយៈកម្មវិធីឌីជីថលកម្ពុជាឆ្នាំ២០១៩។
- ភាពមិនទាន់ពេញលេញនិងគ្រប់ជ្រុងជ្រោយនៃក្របខ័ណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត បានបង្អាក់ការអភិវឌ្ឍក្នុងវិស័យប្រៃសណីយ៍ និងទូរគំនាគមន៍។

34

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច (ត)

### ៤.២- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ

- បានជំរុញការអនុវត្ត និង ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មសម្រាប់ឆ្នាំ២០១៧-២០១៨ ។
- បានចុះបញ្ជីគម្រោងវិនិយោគថ្មីក្នុងតំបន់សេដ្ឋកិច្ចពិសេសចំនួន៤១ គម្រោង នៅឆ្នាំ២០២០។
- បាននិងកំពុងដំណើរការ កិច្ចសហប្រតិបត្តិការទេសចរណ៍ភាគខាងត្បូង(កម្ពុជា ថៃ វៀតណាម) និងកិច្ចសហប្រតិបត្តិការទេសចរណ៍តំបន់ត្រីកោណ(កម្ពុជា ឡាវ វៀតណាម) d;mjbI ពង្រីកវិស័យទេសចរណ៍។

35

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច (ត)

### ៤.២- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ (ត)

- រាជរដ្ឋាភិបាល បានរៀបចំនិងអនុម័ត ផែនការមេអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ខេត្តកែប ខេត្តមណ្ឌលគិរី (២០២១-២០៣៥) និងគោលនយោបាយអេកូទេសចរណ៍ជាតិ(២០១៩-២០៣០) ។
- រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមពិព័រណ៍ទេសចរណ៍អន្តរជាតិជាច្រើន លើកនៅអាស៊ាន អឺរ៉ុប កូរ៉េ រុស្ស៊ី អាម៉េរិក ឥណ្ឌា និងមជ្ឈិមបូព៌ា ដើម្បីធ្វើទីផ្សារទេចរណ៍កម្ពុជា។
- រាជរដ្ឋាភិបាលកម្ពុជា បានអភិវឌ្ឍការធ្វើពិពិធកម្មផលិតផលរួមមាន ដំឡូងមី, ស្វាយចន្ទី ផលិតផលហាឡាលកម្ពុជា កសិពាណិជ្ជកម្មកម្ពុជា និងជំរុញវិស័យស្មូនដី និង ស្រាវជ្រាវ ប្រមូលទិន្នន័យផលិតផលសក្តានុពលនានា។

36

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច (ត)

### ៤.៣- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលនិងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤

- រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ដែលក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានតួនាទីស្នូលក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។
- អភិវឌ្ឍគោលនយោបាយនិងកិច្ចការនីតិកម្មក្នុងវិស័យពាណិជ្ជកម្ម។
- បានអភិវឌ្ឍសហគ្រិនភាពនិងរបៀបរបបនៃការធ្វើធុរកិច្ច។
- បានបង្កើត“ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍” ដែលនឹងក្លាយជាយន្តការដឹកនាំ និងតម្រង់ទិសដ៏មានប្រសិទ្ធភាព សម្រាប់ជួយជំរុញល្បឿន អភិវឌ្ឍន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៅកម្ពុជា។

37

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច (ត)

### ៤.៣- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលនិងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤ (ត៍)

- ព្រឹត្តិការណ៍សំខាន់ៗរបស់ជាតិនិងអន្តរជាតិត្រូវបានប្រព័ន្ធឃោសនារបស់រដ្ឋផ្សព្វផ្សាយ យ៉ាងទូលំទូលាយ។
- ប្រជាពលរដ្ឋខ្មែរនៅក្នុងប្រទេសប្រមាណ៨៥% បានទទួលសេវាផ្តល់ព័ត៌មាន ផ្តល់ការអប់រំ និងការកម្សាន្ត ប្រកបដោយគុណភាពនិងសមធម៌ តាមរយៈមធ្យោបាយ ផ្សេងៗគ្នា ដូចជាទូរទស្សន៍ វិទ្យុ សារព័ត៌មានបោះពុម្ព និងមធ្យោបាយផ្សេងៗ។

38

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច (ត)

**៤.៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ**

- ធនាគារជាតិនៃកម្ពុជាទទួលបានជោគជ័យក្នុងការបន្តរក្សាអតិផរណាមានកម្រិតទាបក្នុងរង្វង់៣% និងអត្រាប្តូរប្រាក់៤.០៧៨រៀល ក្នុង១ដុល្លារអាម៉េរិក រវាងឆ្នាំ២០១៩ និងឆមាសទី១ ឆ្នាំ ២០២១។
- ធនាគារជាតិនៃកម្ពុជា បានកែលម្អការអនុវត្តតាមស្តង់ដាបាសែលស្តីពីការត្រួតពិនិត្យ ធនាគារប្រកបដោយប្រសិទ្ធភាព ជាពិសេសផ្តោតលើការគ្រប់គ្រងហានិភ័យ។

39

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច(ត)

**៤.៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ (ត)**

- បទប្បញ្ញត្តិមួយចំនួន ដូចជាដើមទុនតាមបទប្បញ្ញត្តិ ហានិភ័យឥណទាន ហានិភ័យទីផ្សារ និងហានិភ័យប្រតិបត្តិការ ត្រូវបានពិនិត្យឡើងវិញ និងបានកែសម្រួលបទប្បញ្ញត្តិទាំងនោះ។
- បានផ្តួចផ្តើមរៀបចំយុទ្ធសាស្ត្រជាតិស្តីពី បរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ ២០១៩-២០២៥។

40

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច

#### ៤.៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ (ត)

- កម្ពុជាបានដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធបាគងដែលជាប្រព័ន្ធទូទាត់កន្លោងនិងប្រព័ន្ធរីថែលផេ ដើម្បីសម្រួលការផ្ទេរប្រាក់និងការទូទាត់សងប្រាក់ឆ្លងគ្រឹះស្ថាន តាមរយៈប្រព័ន្ធអេឡិចត្រូនិក។
- ខេអេចឃ្យូអរកូដ (KHQR Code) ដែលជាស្តង់ដាឃ្យូអរកូដ (QR Code) សម្រាប់ការទូទាត់នៅក្នុងប្រទេសកម្ពុជា ក៏ត្រូវបានបង្កើតឡើងនិងដាក់ឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអនុវត្ត ។

41

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៤- ការធ្វើពិពិធកម្មសេដ្ឋកិច្ច (ត)

#### ៤.៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ (ត)

- អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានរៀបចំពង្រឹងនិងដាក់ឱ្យអនុវត្តក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។
- កម្រិតដុល្លារូបនីយកម្មខ្ពស់ នៅតែជាបញ្ហាប្រឈមសម្រាប់ការរក្សាស្ថិរភាពថ្លៃនិងអត្រាប្តូរប្រាក់នៅកម្ពុជា។
- ធនាគារជាតិនៃកម្ពុជាបានទទួលជំនួយបច្ចេកទេសពីមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក ដើម្បីបណ្ដុះបណ្ដាលនិងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីដំណោះស្រាយពិសេស។

42

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ

**៥.១- ការអភិវឌ្ឍទីផ្សារការងារ**

- រាជរដ្ឋាភិបាលកម្ពុជា បានការដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ២០១៩-២០២៣។
- បន្តជំរុញការអនុវត្តនូវក្របខ័ណ្ឌគោលនយោបាយនានា។
- បានពង្រឹងការអនុវត្តច្បាប់ស្ដីពីការងារ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការចុះធ្វើអធិការកិច្ចក្នុងពេលតែមួយ។
- បានពង្រឹងយន្តការដោះស្រាយវិវាទការងារ ការដោះស្រាយកូដកម្មបាតុកម្ម តាមរយៈគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្មបាតុកម្មនៅតាមគ្រប់មុខសញ្ញា។

43

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ (ត)

**៥.១- ការអភិវឌ្ឍទីផ្សារការងារ (ត)**

- បានបង្កើតក្រុមការងារដោះស្រាយការរីករាលដាលនៃជំងឺកូវីដ-១៩ តាមបណ្ដារោងចក្រ សហគ្រាសនានា ក្នុងរាជធានី ខេត្ត ។
- បានពង្រឹងនិងពង្រីកយន្តការ "វេទិកាការងារ" ដោយបានរៀបចំពិព័រណ៍ការងារ ទិវាជ្រើសរើសកម្លាំងពលកម្មថ្នាក់ជាតិនិងនៅតាមមូលដ្ឋាន។
- ការអនុវត្តសិទ្ធិសេរីភាពសហជីពផ្ដួយពីលក្ខន្តិកៈសហជីព ការមិនគោរពភាពជាតំណាងបំផុត និងបទប្បញ្ញត្តិជាធរមានដែលមិនស្របតាមច្បាប់ស្ដីពីសហជីព បណ្ដាលឱ្យកើតមានវិវាទ។

44

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ (ត)

### ៥.២- ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព

- រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តគោលនយោបាយលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសធុនតូចនិងមធ្យម និងការលើកទឹកចិត្តផ្នែកឥណទាន។
- បានបញ្ចប់សេចក្តីព្រាងគោលនយោបាយលើកទឹកចិត្ត សហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម។
- ផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ បានធ្វើឱ្យការជំរុញដំណើរការរោងចក្រ ការបង្កើតរោងចក្រថ្មី និងមូលដ្ឋានរោងចក្រសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម បានជួបឧបសគ្គ និងមានតួលេខថយចុះដែលមិនធ្លាប់មានពីមុន ។
- ខ្វះធនធានមនុស្សមានសមត្ថភាព ជាពិសេសផ្នែកអភិវឌ្ឍវិធីសាស្ត្របច្ចេកវិទ្យាព័ត៌មាន សម្រាប់រៀបចំប្រព័ន្ធអនឡាញ។

45

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ (ត)

### ៥.២- ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព (ត)

- បានអនុវត្តគោលនយោបាយជាអាទិភាពក្នុងការទាក់ទាញការវិនិយោគដើម្បីបង្កើតចង្កោមសហគ្រាសធុនតូចនិងមធ្យម។
- បាននិងកំពុងគិតគូរផ្តល់ការលើកទឹកចិត្តដល់ការវិនិយោគ បង្កើតបណ្តុំសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព នៅក្នុងសេចក្តីព្រាងច្បាប់ថ្មីស្តីពីវិនិយោគ។
- អភិវឌ្ឍកិច្ចការស្រាវជ្រាវនិងបណ្តុះបណ្តាលពាណិជ្ជកម្ម។
- អភិវឌ្ឍកិច្ចការពាណិជ្ជកម្មនៅតាមរាជធានី ខេត្ត។

46

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ (ត)

### ៥.៣- ការរៀបចំនិងអនុវត្តភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជន

- រាជរដ្ឋាភិបាលកម្ពុជា បានពង្រឹងការអភិវឌ្ឍវិស័យឯកជន ដោយបានរៀបចំអនុក្រឹត្យស្តីពីការទទួលស្គាល់សមាជិកសភាពាណិជ្ជកម្មខេត្ត រៀបចំប្រកាសស្តីពីការទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្មខេត្ត និងរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតក្រុមការងាររៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រតិបត្តិនិងក្រុមប្រឹក្សាភិបាលនៃសមាគមលើកកម្ពស់ម្រេចកំពត។
- ពង្រឹងនិងពង្រីកកិច្ចការសម្រួលពាណិជ្ជកម្ម។

47

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៥- ការអភិវឌ្ឍវិស័យឯកជននិងការងារ (ត)

### ៥.៤- ការពង្រឹងការប្រកួតប្រជែង

- រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំនិងចូលរួមកសាងសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង និងគោលនយោបាយប្រកួតប្រជែងអាស៊ាន និង
- បានតាមដានត្រួតពិនិត្យ និងសម្របសម្រួលជាប្រចាំលើបញ្ហាពាក់ព័ន្ធនឹងការប្រកួតប្រជែងដោយមិនស្មោះត្រង់។
- បានពង្រឹងយន្តការដោះស្រាយវិវាទពាណិជ្ជកម្ម។

48

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន

#### ៦.១- ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ

- រាជរដ្ឋាភិបាលកម្ពុជាបានចុះកិច្ចព្រមព្រៀងជាមួយក្រុមការងារកាវ៉ាក់ ក្នុងកិច្ចសហប្រតិបត្តិការកម្មវិធីខ្សែច្រវ៉ាក់ តម្លៃកសិកម្មកម្ពុជា អូស្ត្រាលី ស្តីពីការលើកកម្ពស់ការវិនិយោគក្នុងវិស័យកសិចំណីអាហារ នៅកម្ពុជា។
- បង្កើនផលិតភាពផលិតកម្មផ្នែកកសិកម្ម ។
- ពង្រឹងនិងពង្រីកនូវសន្តិសុខស្បៀង។
- រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទ ឆ្នាំ ២០១៤-២០២៥។

49

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន (ត)

#### ៦.១- ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ (ត)

- គិតត្រឹមពាក់កណ្ដាលឆ្នាំ២០២១ ផ្ទៃដីដាំដុះដំណាំកសិកម្មសរុប សម្រេចបាន៣,៤៧៥លានហិកតា ក្នុងនោះផ្ទៃដីដាំដុះដំណាំស្រូវ មានចំនួន២,៦៣៣លានហិកតា។
- ការនាំចេញផលិតផលកសិកម្មសម្រេចបាន៤,៤៥លានតោន។
- ចាប់ពីឆ្នាំ២០១៩ដល់ត្រឹមពាក់កណ្ដាលឆ្នាំ២០២១នេះ ផលិតកម្មសត្វមានការកើនពី៤៥,៨៥លានក្បាលនៅឆ្នាំ២០១៩ កើនដល់ ៥៣,៩០លានក្បាល នៅឆ្នាំ២០២០ គឺកើនលើសឆ្នាំ២០១៩ចំនួន ១៧,៦%។

50

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន (ត)

### ៦.១- ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ (ត)

- ផលិតភាពក្នុងការដាំដុះ ក៏ដូចជាការចិញ្ចឹមសត្វនៅមានកម្រិតទាបនៅឡើយ ដែលបញ្ហាប្រឈមខ្លាំងក្នុងការប្រកួតប្រជែងទីផ្សារ ពិសេសថ្លៃដើមផលិតកម្មរបស់កសិករនៅមានកម្រិតខ្ពស់។
- ប្រព័ន្ធស្រោចស្រពកសិកម្មនៅពុំទាន់បានគ្របដណ្ដប់លើផ្ទៃដីដាំដុះឱ្យបានទូលំទូលាយ។

51

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន (ត)

### ៦.១- ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ (ត)

- រាជរដ្ឋាភិបាលកម្ពុជា បានផ្ដោតការយកចិត្តទុកដាក់លើការជួសជុលស្ដារឡើងវិញ និងសាងសង់ប្រព័ន្ធធារាសាស្ត្រទាំងតូចទាំងធំនៅទូទាំងប្រទេសក្នុងឆ្នាំ២០១៩-២០២១។
- បានសាងសង់ដំឡើង ជួសជុល កែលម្អ ស្ថានីយឧតុនិយម និងដំឡើងប៉ុស្តិ៍តម្រងទឹកភ្លៀង។
- ផ្ដោតការយកចិត្តទុកដាក់លើ ការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ។
- រាជរដ្ឋាភិបាលកម្ពុជា បានបន្តដឹកនាំនិងសម្របសម្រួលរៀបចំរចនាសម្ព័ន្ធការងារនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

52

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន (ត)

### ៦.១- ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ (ត)

- បានរៀបចំឯកសារគតិយុត្តសំខាន់ៗ រៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ។
- បានសហការនិងចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីជាមួយនឹង វិស័យឯកជន គ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័នសិក្សាស្រាវជ្រាវ ក្នុងការផលិតផលិតផលខ្មែរ។
- កង្វះខាតបុគ្គលិកសកម្មនិងមានការយល់ដឹងខ្ពស់លើដំណើរការអនុវត្តការងារជំរុញចលនា ភូមិមួយផលិតផលមួយ។

53

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន (ត)

### ៦.២- ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព

- រាជរដ្ឋាភិបាលកម្ពុជា បានបន្តអនុវត្តគោលនយោបាយជាតិស្តីពីធនធានរ៉ែឆ្នាំ២០១៨-២០២៨ ដោយពង្រឹងអភិបាលកិច្ចលើការធ្វើប្រតិបត្តិការធនធានរ៉ែ។
- បានរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការគ្រប់គ្រងកន្លែងអភិរក្សជលផល ការបង្ក្រាបបទល្មើសជលផល ការអភិវឌ្ឍវារីវប្បកម្ម ការសិក្សាស្រាវជ្រាវនិងការផ្សព្វផ្សាយ។
- បានចេញប្រកាសបង្កើតសហគមន៍ព្រៃឈើថ្មីចំនួន៥០សហគមន៍ គ្របដណ្តប់លើផ្ទៃដី១២ ១៦៦ហិកតា។

54

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន(ត)

### ៦.២- ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព (ត)

- យកចិត្តទុកដាក់លើការបង្កើតមុខរបរបន្ថែមដល់ប្រជាសហគមន៍ក្នុងការបង្កើនចំណូលនិងលើកកម្ពស់ជីវភាពរស់នៅ។
- បានរៀបចំបង្កើតតំបន់ការពារធម្មជាតិ ដែលបច្ចុប្បន្នមានផ្ទៃដីសរុបជាង ៧លានហ.ត. ឬស្មើប្រមាណ៤១% នៃផ្ទៃដីសរុបរបស់ប្រទេសកម្ពុជាក្នុងនោះ។
- បានសហការទប់ស្កាត់បទល្មើសធនធានធម្មជាតិទ្រង់ទ្រាយធំនៅតំបន់ការពារធម្មជាតិ និងរបៀង អភិរក្សជីវៈចម្រុះ។

55

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន(ត)

### ៦.២- ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព (ត)

- អនុវត្តគម្រោងឥណទានកាបូនក្នុងតំបន់ការពារធម្មជាតិជាមួយដៃគូអន្តរជាតិ។
- បានពិនិត្យនិងអនុម័តប្លង់មេលើគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិ។
- បានចុះពង្រឹងប្រសិទ្ធភាពសេវាប្រមូលនិងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនរាជធានី ក្រុង ស្រុក។
- បានពង្រឹងនិងពង្រីកសកម្មភាពអប់រំបរិស្ថាន ដល់គ្រឹះស្ថានសិក្សាសាធារណៈគ្រប់កម្រិត និងវត្តអារាម។
- មានភាពស្មុគស្មាញក្នុងការដោះស្រាយទំនាស់ក្នុងការប្រើប្រាស់ដីនៅក្នុងនិងជុំវិញតំបន់ការពារធម្មជាតិ

56

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន(ត)

### ៦.២- ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព (ត)

- បានជួសជុលនិងអភិរក្សសំណង់បុរាណសរុបប្រមាណ១០៩សំណង់។
- បាននិងកំពុងរៀបចំឯកសារដើម្បីស្នើសុំចុះ "ប្រាសាទកោះកេរ" "នំបញ្ចុក" "ក្បាច់គុនល្បុក្កតោ" និងទីក្រុងបាត់ដំបង ទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក បញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ និងបណ្ដាញទីក្រុងដែលមានភាពច្នៃប្រឌិតរបស់អង្គការយូណេស្កូ។
- បានយកចិត្តទុកដាក់និងសហការជាមួយសហគមន៍ក្នុងការបណ្ដុះបណ្ដាលនិងរៀបចំការសម្ដែងសិល្បៈ។
- ខ្វះធនធានមនុស្សនិងហិរញ្ញវត្ថុ ដើម្បីអនុវត្តការងារ។

57

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន (ត)

### ៦.៣- ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម

- បានបន្តចុះបញ្ជីចេញបណ្ណកម្មសិទ្ធិដី និង បានបន្តចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។
- បានបញ្ចប់គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន៣៤ខ្សែ។
- បានរៀបចំគោលនយោបាយនិងលិខិតគតិយុត្តទាក់ទងនឹងការអភិវឌ្ឍទីក្រុង ដូចជាច្បាប់ភូមិបាល(ថ្មី) ច្បាប់ស្ដីពីលំនៅឋាន ច្បាប់ស្ដីពីការរៀបចំដែនដីនិងនគរូបនីយកម្ម។
- បញ្ហាប្រឈមមួយចំនួន ដូចជាត្រូវការ ការផ្គត់ផ្គង់ទឹកស្អាត ការគ្រប់គ្រងសំណល់ ប្រព័ន្ធលូ ជាដើម ដើម្បីបំពេញតម្រូវការនៃកំណើនសំណង់និងការវិនិយោគលើលំនៅឋានដែលមានតម្លៃសមរម្យសម្រាប់ប្រជាជនកម្ពុជា។

58

## ២. ខ្លឹមសារសំខាន់ៗ របស់របាយការណ៍ពាក់កណ្ដាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ (ត)

### ៦- ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន (ត)

៦.៤- ការធានាចីរភាពបរិស្ថាននិងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

- បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការអភិវឌ្ឍន៍ទីក្រុងនិរន្តរភាពសម្រាប់រាជធានីភ្នំពេញ ឆ្នាំ២០១៨-២០៣០ ដោយមានភ្ជាប់នូវគម្រោងវិនិយោគទីក្រុងបៃតង/និរន្តរភាព។
- បរិមាណឧស្ម័នផ្ទះកញ្ចក់ដែលបានកាត់បន្ថយធៀបទិន្នន័យឆ្នាំគោល ២០១៨ និងគោលដៅ ឆ្នាំ២០១៩ មានចំនួន២,៨០ GgCO2 សមមូល និង ២០២០ មានចំនួន២,៨៤ GgCO2 សមមូល ដែលបានគណនាតាមយន្តការអភិវឌ្ឍន៍ស្អាតនឹងយន្តការឥណទានកាបូនរួមគ្នា។
- កម្រិតត្រៀមរបស់ស្ថាប័ន ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ធៀបទិន្នន័យឆ្នាំគោល២០១៨(៤៩%) និងគោលដៅឆ្នាំ២០១៩(៥៣%)។

59

## ៣. តម្លៃដែលត្រូវចំណាយ ធនធាន និងការកំណត់កម្មវិធីចំណាយ

- សម្រាប់រយៈពេលពាក់កណ្ដាលអាណត្តិទៀតដែលនៅសល់ របស់ ផ.យ.អ.ជ. រាជរដ្ឋាភិបាលកម្ពុជានឹងត្រូវការទុនវិនិយោគមូលធនសរុបចំនួន ២៧ ៨៧១លានដុល្លារអាម៉េរិក សមមូល ១១៣ ១៥៦ពាន់លានរៀល ដែលក្នុងនោះ៖
  - វិនិយោគមូលធននៃវិស័យសាធារណៈ មានចំនួន៧ ៧០៦,៥លានដុល្លារអាម៉េរិក សមមូល ៣១ ២៨៨ពាន់លានរៀល ប្រមាណ ២៧,៧% នៃទុនវិនិយោគសរុប។
  - វិនិយោគមូលធនរបស់វិស័យឯកជន មានចំនួន ២០ ១៦៥,៥ លានដុល្លារអាម៉េរិក សមមូល៨១ ៨៧១ពាន់លានរៀល ប្រមាណ ៧២,៣%នៃទុនវិនិយោគសរុប។

60

## ៤. សេចក្តីសន្និដ្ឋាន

- ការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ ក្នុងរយៈ ពាក់កណ្តាលអាណត្តិ ពីខែមករា ២០២៩ ដល់ ខែមិថុនា ឆ្នាំ២០២១ កន្លងទៅនេះ ចំពេលដែលមានការរីករាលដាលយ៉ាងធ្ងន់ធ្ងរនៃកូវីដ-១៩។
- ទោះជាដូចនេះក្តី គោលដៅដែលគ្រោងទុកភាគច្រើន មិនអាចសម្រេចបានទេ នៅក្នុងអំឡុងពេលនេះ។
- រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងគ្រប់គ្រងកូវីដ-១៩ បានយ៉ាងល្អ ទោះបីជាមិនទាន់បំបាត់បានទាំងស្រុង តែអាចការពារ និងមិនឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ការធ្វើអាជីវកម្ម និងការអភិវឌ្ឍសេដក្ខកិច្ចកម្ពុជាទេ។

61

## ៤. សេចក្តីសន្និដ្ឋាន (ត)

- រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំយុទ្ធសាស្ត្រស្តារសេដ្ឋកិច្ច សង្គមនៅក្រោយកូវីដ-១៩ ដើម្បីលើកកម្ពស់ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ។
- ជាមួយគ្នានេះ តាមរយៈការរៀនសូត្រពីបទពិសោធន៍កន្លងទៅ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងរៀបចំកិច្ចដំណើរការសេដ្ឋកិច្ច និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច តាមបែបគន្លងថ្មី។
- ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានរៀបចំការត្រៀមខ្លួនឱ្យបានរឹងមាំ សម្រាប់ប្រឈមនឹងបញ្ហាថ្មីៗផ្សេងទៀត ដែលអាចលេចឡើងតាមរយៈកិច្ចសហប្រតិបត្តិការ ជាមួយភាគីពាក់ព័ន្ធ ទាំងក្នុង និងក្រៅ រាជរដ្ឋាភិបាល និង ទាំងក្នុង នឹងក្រៅប្រទេស។

62

# សូមអរគុណ !

63